# ចប់ "វាសនានាងមាលា"



គម្រោង TIGER ត្រូវបានអនុវត្តក្រោមកិច្ចសហការរបស់

vvob education for development

# វាសនា "នាង មាលា"



រៀបចំដោយ

សហការឧបត្ថម្ភដោយ

Belgium partner in development

Flanders State of the Art

បោះពុម្ពផ្សាយដោយ៖

**© 2020 VVOB -** ការអប់រំដើម្បីការអភិវឌ្ឍន៍

Julien Dillensplein 1 bus 2A, 1060 Brussels, Belgium

ទូរស័ព្ទ៖ +32 2 209 07 99; គេហទំព័រ៖ www.vvob.org

**សិទ្ធិ និងការអនុញ្ញាត**

អ្នកនិពន្ធដែលទទួលខុសត្រូវ៖

Sven Rooms

© 2020 VVOB vzw

កែសម្រួល និងរចនាដោយ GIM Publishing

រាល់ការបោះពុម្ពផ្សាយឯកសារត្រូវបានធ្វើឡើងដោយអនុលោមតាមអាជ្ញាប័ណ្ណ:

Creative Commons Attribution-Non Commercial-Share Alike 4.0 International License

(CC BY-NC-SA 4.0)

ក្រោមអាជ្ញាបណ្ណនេះ អ្នកអាចថតចម្លង ចែកចាយ បញ្ជូន និងប្រែសម្រួលឯកសារនេះក្នុងន័យមិនរកកម្រៃ។ រាល់សំណួរដែលពាក់ព័ន្ធនឹងសិទ្ធិ និងអាជ្ញាបណ្ណខាងលើ សូមទំនាក់ទំនងសួរមកកាន់ការិយាល័យ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ តាមរយ:អាសយដ្ឋាន Julien Dillensplein 1 bus 2A, 1060 Brussels, Belgium - ទូរស័ព្ទ៖ +32 2 209 07 99; អ៊ីមែល៖ info@vvob.org; គេហទំព័រ៖ www.vvob.org

**ឯកសារមិនរាប់បញ្ចូល និងរក្សាសិទ្ធិ**

ឯកសារនេះ ត្រូវបានផលិតឡើងក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្វ្លែមីស៍។ ខ្លឹមសារនៃឯកសារនេះស្ថិតក្រោមការទទួលខុសត្រូវរបស់ VVOB - ការអប់រំដើម្បីការអភិវឌ្ឍន៍ ហើយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍ទាំងនេះទេ។

សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្វ្លែមីស៍មិនទទួលខុសត្រូវចំពោះខ្លឹមសារនៅក្នុងឯកសារនេះទេ។

សហការឧបត្ថម្ភថវិកាដោយ៖

ឯកសារនេះជាសមិទ្ធផលដែលចូលរួមសហការចងក្រងដោយ៖

“មាលា ជាសិស្សពូកែម្នាក់ប្រចាំសាលា មានមិត្តរួមថ្នាក់ដែលជាក្មេងប្រុសៗមួយក្រុម តែងតែប្រើពាក្យលែបខាយដាក់នាង ហើយពួកគេធ្វើឱ្យនាងមានអារម្មណ៍មិនសប្បាយចិត្តជាខ្លាំង។ ថ្ងៃមួយពេលនាងដើរចូលថ្នាក់រៀនបន្ទាប់ពីម៉ោងចេញលេង ក្មេងប្រុសៗទាំងនោះបានបង្ហាញរូបភាពស្ត្រីម្នាក់អាក្រាតកាយក្នុងទូរស័ព្ទរបស់ពួកគេឱ្យនាងមើល។”



“មាលាមានអារម្មណ៍ខ្មាសអៀនយ៉ាងខ្លាំង និងមិនសប្បាយចិត្តទៀតផង។ នាងបានរៀបរាប់ប្រាប់មិត្តរបស់នាងពីសកម្មភាពដែលក្មេងប្រុសទាំងនោះតែងតែធ្វើដាក់នាង។ មិត្តភិក្តរបស់មាលាមានអារម្មណ៍មិនសប្បាយចិត្តដូចនាងដែរ។ បន្ទាប់មកពួកនាងបាននាំគ្នាទៅនិយាយជាមួយក្មេងប្រុសៗទាំងនោះ និងប្រាប់ពួកគេឱ្យឈប់រំខាននាងទៀត។”



ក្មេងប្រុសៗទាំងនោះមិនខ្វល់ឡើយ នៅថ្ងៃបន្ទាប់ពួកគេនៅតែបន្តរំខានមាលាដដែល ថែមទាំងរំខាននាងនៅខាងក្រៅសាលារៀនថែមទៀត។



“

គ្រូរបស់ពួកគេបាននិយាយថាពួកនាងធ្វើត្រឹមត្រូវហើយដែលយករឿងកើតឡើងនោះមកប្រាប់គាត់ទាន់ពេល។ សាលាមានគោលនយោបាយទប់ស្កាត់ការរំលោភបំពាននានា ហើយក្មេងប្រុសៗទាំងនោះត្រូវគោរពគោលនយោបាយនោះ។ បន្ទាប់មកគ្រូបាននិយាយថា គ្រូនឹងនិយាយជាមួយក្មេងប្រុសទាំងនោះ។

”



ដោយសារតែក្មេងប្រុសៗទាំងនោះចាប់ផ្តើមរំខាននាងនៅខាងក្រៅសាលារៀនក៏ដូចជានៅក្នុងសាលារៀន គ្រូបង្រៀនសម្រេចចិត្តចូលរួមជាមួយគណៈគ្រប់គ្រងសាលាដើម្បីដោះស្រាយបញ្ហានេះ។ គណៈគ្រប់គ្រងសាលាបានអញ្ជើញឪពុកម្តាយក្មេងប្រុសៗនោះមកពិភាក្សា។



# ចក្ខុវិស័យ

សាលារៀនជាធនធានដ៏សំខាន់របស់សហគមន៍ដែល
ផ្តល់ចំណេះដឹង ចំណេះធ្វើ និងឥរិយាបទដល់សិស្សគ្រប់រូប ប្រកបដោយគុណភាព។

“ឪពុកម្តាយក្មេងប្រុសៗបានមកសាលាដើម្បីជជែករកដំណោះស្រាយជាមួយគណៈគ្រប់គ្រងសាលា។ ការចូលរួមរបស់ឪពុកម្តាយគឺជាដំណោះស្រាយដ៏ល្អបំផុតសម្រាប់មាលា។”



“ក្រៅពីនេះ គ្រូបានលើកឡើងពីសកម្មភាពដែលក្មេងប្រុសទាំងនោះធ្វើដាក់ម៉ាលាមកអប់រំណែនាំ។ ហើយគាត់ផ្តល់មេរៀនរបៀបដោះស្រាយបញ្ហាដោយយកចិត្តទុកដាក់ទៅលើក្មេងប្រុស និងក្មេងស្រី នៅសាលារៀននិងក្នុងសង្គម។ បន្ទាប់មកក្មេងប្រុស និងក្មេងស្រីមានការយល់ដឹងកាន់តែច្បាស់អំពីអ្វីដែលជាព្រំដែនផ្ទាល់ខ្លួននិងអាកប្បកិរិយាដែលមិនអាចទទួលយកបានហើយដឹងថាមានគោលនយោបាយសមភាពយេនឌ័រផងដែរ។”



“ចាប់តាំងពីពេលនោះមកមាលា និងមិត្តរួមថ្នាក់បានសហការគ្នាជជែកជាមួយក្មេងប្រុសៗទាំងនោះ។ ក្មេងប្រុសៗទាំងនោះក៏បញ្ឈប់សកម្មភាពរំខាននាង។”

